ទស្សនៈ
អ្នកនិពន្ធ

វ៉ុល៣, លេខ៧, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១

# "ប្រក្រតីភាពតាមគន្លងថ្មី"៖ របត់បណ្ដោះអាសន្ន ឬទៅរកសណ្ដាប់ធ្នាប់ថ្មី?

អ៊ុន លាង *

វត្តមានជំងឺកូវីដ១៩ ដែលបានចាប់ផ្ដើមឡើងនៅចុងឆ្នាំ ២០១៩ បាននិងកំពុងធ្វើឱ្យពិភពលោកទាំងមូលធ្លាក់ក្នុងវិបត្តិដ៏ធ្ងន់ធ្ងរ ដែលក្នុងនោះមានមនុស្សឆ្លងសរុបនៅទូទាំងពិភពលោកចំនួន ១៤៧,៣១៧,៣២៩នាក់ និងស្លាប់ចំនួន ៣,១១៦,០១២នាក់[1]។ មុនពេលមានអ្នកស្លាប់ដំបូងនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ កម្ពុជាត្រូវបានពិភពលោកកោតសរសើរអំពីការគ្រប់គ្រងបានយ៉ាងល្អ ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។ ប៉ុន្តែជាមួយចំនួនអ្នកស្លាប់កើនដល់ ៧៤នាក់ និងមានអ្នកឆ្លងសរុបចំនួន ៩,៩៧៥នាក់ (អ្នកជាសះស្បើយពីជំងឺមានចំនួន ៣,៤០០នាក់) គិតត្រឹមថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១[2] កម្ពុជាត្រូវបានគេសង្កេតឃើញថា កំពុងស្ថិតនៅលើមាត់ជ្រោះមរណៈ។

តើជ្រោះមរណៈនេះមានជម្រៅប៉ុណ្ណា? នៅក្នុងចំណោមប្រទេសដែលមានទិន្នន័យចំនួន ២២១ប្រទេស កម្ពុជាឈរនៅលើលេខរៀងទី១៥៤ នៃអ្នកឆ្លងជំងឺកូវីដ១៩ ច្រើនជាងគេ ឈរលើលេខរៀងទី១៦៦ នៃចំនួនមានអ្នកស្លាប់ច្រើនជាងគេ និងឈរលើលេខរៀងទី១៩៣ នៃចំនួនអ្នកស្លាប់ច្រើនជាងគេក្នុងចំណោមប្រជាជនមួយលាននាក់[3]។ ប្រសិនបើយើងប្រៀបធៀបជ្រោះមរណៈនេះក្នុងកម្រិតសាកលលោក ជ្រោះនៅកម្ពុជានេះមិនជ្រៅទេ។ ប៉ុន្តែរាជរដ្ឋាភិបាលមិនបានលេងសើចជាមួយជ្រោះមរណៈនេះទេ។ រាជរដ្ឋាភិបាលបាន និងកំពុងធ្វើសកម្មភាព និងចាត់វិធានការយ៉ាងសកម្ម ដើម្បីបញ្ចៀសកម្ពុជាឱ្យចេញផុតពីមាត់ជ្រោះមរណៈនេះ។ វិធានការដែលចេញក្នុងពេលថ្មីៗនេះ រួមមានការផាកពិន័យ ការដាក់ទោស ការផ្អាកចរាចរណ៍ឆ្លងតំបន់ និងចុងក្រោយ គឺការបិទខ្ទប់រាជធានីភ្នំពេញ ទីក្រុងតាខ្មៅទាំងស្រុងក្នុងរយៈពេលពីរសប្ដាហ៍ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ និងថ្មីៗនេះបានបិទខ្ទប់តំបន់មួយចំនួនបន្ថែមទៀតនៃខេត្តក្រុងមួយចំនួនទៀត ដែលការបិទខ្ទប់នេះអាចនឹងត្រូវបានពង្រីកទៅកាន់តំបន់ផ្សេងទៀត និងអាចអូសបន្លាយពេលវេលាវែងជាងនេះទៀត ប្រសិនបើស្ថានភាពនៃការចម្លងមិនមានការថយចុះទេ នេះបើតាមការប្រកាសជាសាធារណៈរបស់ប្រមុខរាជរដ្ឋាភិបាល។

ចេញពីការអនុវត្តវិធានការទាំងនេះ ភាពច្របូកច្របល់បានកើតមានឡើង ហើយគឺចេញពីអ្នកទទួលរងផលប៉ះពាល់នៃការអនុវត្តវិធានការនេះហើយ ដែលពួកគេអះអាងថា ពួកគេកំពុងជួបវិបត្តិ ដោយដំបូង គឺវិបត្តិដែលបណ្ដាលមកពីការធ្លាក់ចុះនៃវិស័យទេសចរណ៍ និងជាពិសេសក្នុងពេលថ្មីៗដែលការចម្លងបានរីករាលដាលដល់រោងចក្រវាយណភណ្ឌ ទីផ្សារលក់ដូរ និងឈានទៅដល់ការបិទផ្សារមួយចំនួន។ អ្នក

[1] និង [3] ដកស្រង់ចេញពី https://www.worldometers.info/coronavirus/ ចូលមើលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១។

[2] ដកស្រង់ចេញពីសេចក្ដីប្រកាសរបស់ក្រសួងសុខាភិបាលកម្ពុជា

*__បណ្ឌិត អ៊ុន លាង__ គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

បង្កើតគោលនយោបាយសាធារណៈ បានប្រឹងប្រែងស្វែងយល់ពីវិបត្តិនេះ ហើយក៏កំពុងខិតខំធ្វើយ៉ាងណាដើម្បីបញ្ចៀសឱ្យផុតពីវិបត្តិចលាចលសង្គមផងដែរ។

ទោះបីរាជរដ្ឋាភិបាលបានប្រឹងប្រែងយ៉ាងខ្លាំងក្លា ទាំងការប្រើប្រាស់ប្រភពធនធានសាធារណៈ និងការកៀរគរជំនួយសប្បុរសធម៌ នៅក្នុងកម្រិតបុគ្គល គេនៅតែឃើញមានវិបត្តិពីរបណ្តាលមកពីកត្តាបាត់បង់ការងារ ដែលលេចធ្លោជាងគេទីមួយ គឺសន្តិសុខស្បៀង ជាពិសេសតាមគ្រួសារដែលរងផលប៉ះពាល់ជាងគេ (វាមានការឡើងថ្លៃម្ហូបអាហារខ្លះៗដែរនៅក្នុងអំឡុងពេលបិទខ្ទប់ប៉ុន្មានថ្ងៃនេះ) និងទីពីរគឺឥណទានធនាគារ ជាពិសេសកម្ចីខ្នាតតូច និងមធ្យម និងកម្ចី/បង់រំលោះទិញអចលនទ្រព្យ (គេហដ្ឋាន)។ វិបត្តិទីបី ដែលកប់បាត់មើលមិនឃើញ ហើយប្រហែលជាប្រភពនៃវិបត្តិពីរខាងលើ គឺវិបត្តិផ្លូវចិត្ត នោះគឺអារម្មណ៍ថា ខ្លួនមិនមានសុវត្ថិភាពគ្រប់គ្រាន់ក្នុងអំឡុងពេលដ៏ពិបាកនេះ និងអ្នកដែលមានជំងឺផ្លូវចិត្តដែលមិនបានរស់នៅក្នុងជីវភាពធម្មតាដែលខ្លួនធ្លាប់រស់នៅ ទោះបីជាមិនមានបញ្ហាពីរខាងលើ ពោលគឺកង្វះស្បៀងអាហារ និងបំណុលក៏ដោយ។ វិបត្តិទីបួនស្ថិតនៅក្នុងកម្រិតប្រទេសជាតិ ដែលជាគ្រឹះនៃវិបត្តិទាំងបីខាងលើ នោះគឺនិរន្តរភាព និងចីរភាពនៃជីវភាពសង្គមដូចដែលធ្លាប់មាន និងគ្រោងថានឹងមាន ដែលរាជរដ្ឋាភិបាលកំពុងព្យាយាមដោះស្រាយ ដោយថ្លឹងថ្លែងយ៉ាងប្រយ័ត្នប្រយែងជាទីបំផុតជាមួយមាត់ជ្រោះមរណៈ ដែលកម្ពុជាកំពុងឈរ ឬកំពុងធ្វើដំណើរទៅកៀកប្រសិនបើមិនមានវិធានការតឹងរ៉ឹង និងម៉ត់ចត់នោះទេ។

ទោះបីជាបានរកឃើញវ៉ាក់សាំង និងដំណើរការចាក់វ៉ាក់សាំងបានរៀបចំខ្លះៗហើយក៏ដោយ ការបារម្ភពីវត្តមានជំងឺកូវីដ ១៩ នៅតែមាននៅឡើយ។ ឧទាហរណ៍ ប្រទេសអ៊ីស្រាអែលជាប្រទេសទីមួយ ដែលមានប្រជាជនពេញវ័យចាក់វ៉ាក់សាំងច្រើនជាងគេ និងបានដកកាតព្វកិច្ចពាក់ម៉ាសនៅតាមទីសាធារណៈចេញ តែនាយករដ្ឋមន្ត្រីនៃប្រទេសនេះ នៅតែបារម្ភថា ជំងឺកូវីដ១៩ អាចនឹងត្រឡប់មកវិញបាន[4]។

ចាប់តាំងពីវិបត្តិដែលលេចចេញជារូបរាងច្បាស់ ទាំងនៅក្នុងកម្រិតអន្តរជាតិ ក៏ដូចជានៅកម្ពុជា វាក្យសព្ទ "ប្រក្រតីភាពតាមគន្លងថ្មី" ត្រូវបានគេប្រើប្រាស់ ដើម្បីសម្រួលអារម្មណ៍ថាយើងនឹងមានសុវត្ថិភាពគ្រប់គ្រាន់។ តែរហូតមកទល់ពេលនេះ ពិភពលោកទាំងមូល រួមទាំងកម្ពុជាផងដែរ មិនទាន់មានសុវត្ថិភាពនៅឡើយទេ។ គេអាចនិយាយបានថា នេះប្រហែលជាបណ្តាលមកពីបញ្ហាដែលថា *មនុស្សគ្រប់គ្នាមិនទាន់មានសមត្ថភាពពេញលេញ និងលទ្ធភាពគ្រប់គ្រាន់សម្រាប់អនុវត្ត "ប្រក្រតីភាពតាមគន្លងថ្មី" នេះ ដើម្បីជានាដំណើរការធម្មតានៃជីវភាពសង្គមឡើងវិញ ឬ "ប្រក្រតីភាពតាមគន្លងថ្មី" មិនបានបង្កើតសណ្តាប់ធ្នាប់ថ្មីមួយសម្រាប់ឱ្យសង្គមមួយ ដែលអាចធានានូវដំណើរការប្រកបដោយនិរន្តរភាព និងចីរភាព*។

ក្នុងន័យនេះ វិបត្តិពិតជានៅមានវត្តមានរស់រវើកនៅឡើយ។ នៅទីនេះ ខ្ញុំនឹងមិនពិភាក្សាអំពីមូលហេតុនៃវិបត្តិនោះទេ។ មានមូលហេតុពីរដែលនាំឱ្យខ្ញុំគិតបែបនេះ។ ទីមួយ ក្នុងនាមជាសាមញ្ញជន មិនមែនជាអ្នកវិទ្យាសាស្ត្រ ខ្ញុំគ្មានអំណាចឯកទេសក្នុងការនិយាយពីជំងឺកូវីដ១៩ នេះទេ។ ហើយជំងឺស្រដៀងគ្នានេះ ដែលបានបង្កើតវិបត្តិផ្សេងៗ បានកើតឡើងជាច្រើនដងមកហើយក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ នេះមិនមែនជាលើកទីមួយនោះទេ។ ទីពីរ វិបត្តិទាំងបួនខាងលើក៏ធ្លាប់កើតមានច្រើនលើកច្រើនសាផងដែរ ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ទោះជាបណ្តាលមកពីមូលហេតុស្រដៀងគ្នាបែបនេះ ឬដោយមូលហេតុផ្សេងទៀត។

អ្វីដែលខ្ញុំនឹងពិភាក្សានោះគឺ **តើអ្វីជាវិបត្តិ?** ក្នុងវចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** ពាក្យវិបត្តិមានន័យច្រើន។ ន័យមួយក្នុងចំណោមនោះ ដែលមនុស្សភាគច្រើនមិនបានយកមកប្រើ គឺសេចក្តីប្រែប្រួល។ ពុទ្ធសាសនាបានយល់ឃើញយ៉ាង

[4] ដកស្រង់ចេញពី https://www.businessinsider.com/israel-unlock-no-outdoor-mask-rule-more-half-vaccinated-2021-4 ចូលមើលថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១។

ច្បាស់ថា មានតែការប្រែប្រួលទេដែលមិនប្រែប្រួល ហេតុនេះ វាគ្មានអ្វីដែលមិនជួបវិបត្តិនោះទេ រួមទាំងដំណើរជីវិតមនុស្ស និងសង្គមផងដែរ។ ក្នុងន័យនេះ ជាដាច់ខាត យើងត្រូវតែជួបនឹងវិបត្តិ ហេតុនេះយើងមិនត្រូវភ័យខ្លាច និងប្រាថ្នាចៀសវៀងពីវិបត្តិនោះទេ ប៉ុន្តែត្រូវក្រសោបយកវិបត្តិ។ នេះមានន័យថា យើងចាត់ចែងការប្រែប្រួលនេះដោយរបៀបណា និងឆ្ពោះទៅអនាគតបែបណា?

ពាក្យវិបត្តិក្នុងភាសាអង់គ្លេស "Crisis" មានឫសគល់ចេញពីភាសាក្រិក "κρίσις" ក្នុងន័យដើមដែលប្រើប្រាស់ក្នុងវិស័យវេជ្ជសាស្ត្រមានន័យថា ចំណុចរបត់នៃជំងឺដែលអាចបណ្តាលឱ្យស្លាប់ ឬជាសះស្បើយបាន និងក្រោយមកទៀត ត្រូវបានប្រើសំដៅលើស្ថានភាពនៃរបត់នៃអ្វីមួយ ការប្រែប្រួលដែលអាចនាំមកនូវភាពប្រសើរ ឬអាក្រក់។ ឫសគល់នៃពាក្យ "κρίσις" មកពីពាក្យ "κρίνειν" [5] ដែលមានន័យច្រើនដូចជា បែងចែក ជ្រើសរើស សម្រេចចិត្ត វិនិច្ឆ័យ រៀបចំឱ្យមានសណ្តាប់ធ្នាប់។ ចេញពីន័យ និងការប្រើប្រាស់ពាក្យទាំងពីរនេះ សុភាសិតជនជាតិក្រិកនិយាយថា គ្រប់វិបត្តិទាំងអស់ផ្តល់ឱ្យយើងនូវកាលានុវត្តភាព ក្នុងការរៀបចំសណ្តាប់ធ្នាប់ឡើងវិញ។

សំណួរដែលត្រូវចោទសួរនៅទីនេះគឺថា តើសណ្តាប់ធ្នាប់បែបណាដែលនឹងត្រូវរៀបចំឡើងវិញ ដើម្បីទៅជំនួសសណ្តាប់ធ្នាប់ចាស់ សំដៅធ្វើយ៉ាងណាឱ្យមនុស្សមានអារម្មណ៍ថា ខ្លួនមានសុវត្ថិភាព និងសង្គមមួយមានដំណើរការជានិរន្តរ និងចីរភាព។

ពាក្យសណ្តាប់ធ្នាប់នៅទីនេះ មានន័យទូលំទូលាយសំដៅលើក្របខណ្ឌដែលគ្រប់គ្រងដំណើរការ នៃអន្តរទំនាក់ទំនងរវាងមនុស្ស និងមនុស្ស និងបែបផែនចង្វាក់ផលិតកម្ម ហើយនិងនិយាមតម្លៃដែលជះឥទ្ធិពលលើអារម្មណ៍ ហើយនិងការគិតរបស់មនុស្សផងដែរ។

ខ្ញុំមិនមានបំណងអះអាងថា វិបត្តិខាងលើកើតឡើងដោយសារតែកត្តាជំងឺកូវីដ១៩ តែមួយនោះទេ ឬក៏គ្មានបំណងអះអាងថា ជំងឺកូវីដ១៩ ជះឥទ្ធិពលតែលើវិបត្តិទាំងបួនខាងលើនោះដែរ។ វិបត្តិខាងលើត្រូវបានលើកឡើង គឺគ្រាន់តែជាឧទាហរណ៍តែប៉ុណ្ណោះ។ ខ្ញុំទទួលស្គាល់ថា វាមានប្រភេទនៃវិបត្តិ និងឫសគល់នៃវិបត្តិច្រើនបែបច្រើនយ៉ាងទៀត ដែលកើតមានចំពោះមនុស្ស និងសង្គមមនុស្ស។ ប៉ុន្តែចេញពីវិបត្តិខាងលើនេះ **ចំណុចរបត់ថ្មីបាន និងកំពុងលេចឡើង** ហើយខ្ញុំសង្ឃឹមថា "**ប្រក្រតីភាពតាមគន្លងថ្មី**" នេះមិនមែនជា "**ប្រក្រតីភាពបណ្តោះអាសន្ន**" **ប៉ុន្តែជារបត់ទៅរកសណ្តាប់ធ្នាប់ថ្មី**។ ជាអ្វីដែលចំណងជើងអត្ថបទនេះ ចង់អំពាវនាវឱ្យមនុស្សទាំងអស់គ្នាធ្វើសកម្មភាព "*ចាប់យកកាលានុវត្តភាពចេញពីវិបត្តិឆ្ពោះទៅរកទៅរកសណ្តាប់ធ្នាប់ថ្មី*"។

នៅកម្រិតបុគ្គល ដូចមានការផ្សព្វផ្សាយពាសពេញបណ្តាញសង្គម សាមគ្គីភាពខ្មែរកាន់តែរឹងមាំឡើងក្នុងពេលវិបត្តិកូវីដ១៩ កុំបង្ហាញភាពហ៊ឺហាហឺកហ៊ាក់នៅពេលប្រជាជនផ្សេងទៀតកំពុងជួបការលំបាក មន្ត្រីដែលមានភារកិច្ចត្រូវមានភាពទន់ភ្លន់ចំពោះប្រជាពលរដ្ឋ ត្រូវចេះគ្រប់គ្រងចំណង់ខ្លួនឯង និងប្រតិបត្តិ "៣កុំ ៣ការពារ"។

នៅក្នុងកម្រិតប្រព័ន្ធ និងសង្គម ការបង្កើតសណ្តាប់ធ្នាប់ថ្មីមិនគ្រាន់តែទាមទារពេលវេលាប៉ុណ្ណោះទេ តែទាមទារឱ្យមានរបត់មួយច្បាស់លាស់ជាងកម្រិតបុគ្គល។ របត់ថ្មីនេះអាចកើតមានបាន លុះត្រាតែយើងមានសមត្ថភាពក្នុងការចោទសួរអំពីសុពលភាពនៃសណ្តាប់ធ្នាប់ចាស់ក្នុងការធានា សុវត្ថិភាពសង្គម ឧទាហរណ៍ចេញពីបញ្ហាសុវត្ថិភាពស្បៀងខាងលើ តើចង្វាក់ផលិតកម្មរបស់យើង រាប់ចាប់តាំងពីការបង្កាត់ពូជរហូតធ្លាក់ដល់មាត់អ្នកហូប តើយើងវាយតម្លៃថាវាស្ថិតនៅ

[5] ដកស្រង់ចេញពី https://www.etymonline.com/word/crisis, https://www.wordsense.eu/%CE%BA%CF%81%CE%AF%CE%BD%CE%B5%CE%B9%CE%BD/ ចូលមើលថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១។

ត្រឹមកម្រិតណាទាក់ទងនឹងសុវត្ថិភាព? ទាក់ទងនឹងឥណទានជាពិសេសកម្ចី/បង់រំលោះទិញអចលនទ្រព្យ (គេហដ្ឋាន) ដែលមានអត្រាការប្រាក់ខ្ពស់ បើប្រៀបធៀបជាមួយនឹងប្រទេសផ្សេងទៀត តើកម្ពុជាគួរតែមានកម្មវិធីគេហដ្ឋានសាធារណៈដូចប្រទេសសិង្ហបុរី[6]ដែរឬទេ?

នៅចុងបញ្ចប់នេះ ខ្ញុំចង់ធ្វើការឆ្លុះបញ្ចាំងថា គ្រប់សណ្ដាប់ធ្នាប់ថ្មីទាំងអស់ដែលនឹងត្រូវបង្កើតឡើង ត្រូវតែដើរតាមនិយាមវិទ្យាសាស្ត្រធម្មជាតិ ដែលក្នុងនោះគ្រប់ស្ថានភាពទាំងអស់ជីវិតត្រូវតែការពារដាច់ខាត (ជីវិតអាចត្រូវបានការពារដោយអំណាចឯកទេសនៃវិទ្យាសាស្ត្រធម្មជាតិផ្សេងៗ) និងនិយាមសង្គម ដែលក្នុងនោះគោលការណ៍យុត្តិធម៌សង្គមត្រូវតែត្រូវបានលើកកម្ពស់ជាដាច់ខាត និងចុងក្រោយពហុភាពបុគ្គលត្រូវតែគោរព តាមរយៈការលើកកម្ពស់តម្លៃសោភ័ណ និងអត្ថន័យនៃជីវិត។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

[6] សិង្ហបុរី ជាប្រទេសដែលចំនួនភាគរយនៃប្រជាជនមានផ្ទះផ្ទាល់ខ្លួនច្រើនជាងគេបំផុតក្នុងពិភពលោក និងប្រជាជន៨០% រស់នៅលើអគារដែលសង់ដោយរដ្ឋាភិបាល។ សូមមើលបន្ថែមតាមរយៈ៖ https://www.bloomberg.com/news/articles/2020-07-08/behind-the-design-of-singapore-s-low-cost-housing។